# ផលផ្លែនៃព្រះវិញ្ញាណ



## សេចក្ដីស្រឡាញ់ ἀγάπη

**ចិត្តមេត្តា ឆន្ទៈល្អ ការគោរព**

“សេចក្ដីស្រឡាញ់តែងតែអត់ធ្មត់ ហើយក៏សប្បុរស សេចក្ដីស្រឡាញ់មិនចេះឈ្នានីស មិនចេះអួតខ្លួន ក៏មិនដែលមានចិត្តធំផង មិនដែលប្រព្រឹត្តបែបមិនគួរសម មិនដែលរកប្រយោជន៍ផ្ទាល់ខ្លួន មិនរហ័សខឹង មិនប្រកាន់ទោស...” (១កូរិនថូស ១៣:៤-៥)

## អំណរអរ χαρà

**សេចក្ដីអរ ឬក៏ត្រេកអរដែលជាប្រភពនៃអំណរ**

“ដែលអ្នករាល់គ្នាមិនបានឃើញទ្រង់ទេ តែបានស្រឡាញ់ទ្រង់ ហើយទោះបើនៅជាន់ឥឡូវនេះ អ្នករាល់គ្នានៅតែមិនឃើញទ្រង់ទៀត គង់តែមានចិត្តជឿដែរ ហើយក៏ត្រេកអរសាទរក្នុងទ្រង់ ដោយសេចក្ដីអំណរដ៏ប្រសើរ ដែលរកថ្លែងមិនបាន...” (១ពេត្រុស ១:៨)

## មេត្រីភាព εἰρήνη

**សេចក្ដីរាប់រក សេចក្ដីរាប់អាន ចិត្តដែលប្រកបដោយសន្តិភាព**

“ដ្បិតទ្រង់ជាស្ពានមេត្រីនៃយើងរាល់គ្នា ទ្រង់បានធ្វើឲ្យទាំង២រួមគ្នាតែ១ ហើយបានរុះជញ្ជាំងដែលខាន់កណ្ដាលចេញ ព្រមទាំងបំបាត់សេចក្ដីសំអប់គ្នា ដោយនូវរូបសាច់ទ្រង់ គឺបំបាត់ក្រិត្យវិន័យដែលមានបញ្ញត្ត នឹងសេចក្ដីហាមប្រាមទាំងប៉ុន្មានចេញ ដើម្បីឲ្យបានយកទាំង២មកបង្កើតជាមនុស្សថ្មីតែ១ក្នុងព្រះអង្គទ្រង់ ដោយតាំងជាស្ពានមេត្រី...” (អេភេសូរ ២:១៤-១៥)

## អត់ធ្មត់ μακροθυμία

**អំណត់ ខន្តី អត់ទ្រាំ ហើយមិនត្អូញត្អែរ**

“ដោយហេតុនោះបានជាទ្រង់អាណិតមេត្តាដល់ខ្ញុំ ដើម្បីឲ្យព្រះយេស៊ូវគ្រីស្ទបានសំដែងចេញ គ្រប់ទាំងសេចក្ដីអត់ធន់របស់ទ្រង់ក្នុងខ្លួនខ្ញុំ ដែលជាអ្នកលេខ១នោះ ឲ្យខ្ញុំបានធ្វើជាក្បួនដល់ពួកអ្នក ដែលនឹងជឿដល់ទ្រង់ ប្រយោជន៍ឲ្យគេបានជីវិតអស់កល្បជានិច្ច។” (១ធីម៉ូថេ ១:១៦)

## សុភាព χρηστότης

**ទៀងត្រង់ សេចក្ដីករុណា ភាពផ្អែមល្ហែម**

“តែកាលសេចក្ដីសប្បុរស របស់ព្រះដ៏ជាព្រះអង្គសង្គ្រោះនៃយើង នឹងសេចក្ដីស្រឡាញ់ របស់ទ្រង់ដល់មនុស្ស បានលេចមកឲ្យឃើញ នោះទ្រង់បានជួយសង្គ្រោះយើង មិនមែនដោយការដែលយើងបានប្រព្រឹត្តដោយសុចរិតនោះទេ គឺដោយសេចក្ដីមេត្តាករុណារបស់ទ្រង់វិញ...” (ទីតុស ៣:៤-៥)

## សប្បុរស ἀγαθωσύνη

**ល្អ សន្ដានចិត្តល្អ ការចូលចិត្តធ្វើល្អ**

“...ដូច្នេះ ចូរដើរដូចជាមនុស្សភ្លឺចុះ ដ្បិតផលផ្លែនៃពន្លឺ នោះមាននៅក្នុងគ្រប់ទាំងកិរិយាល្អ សេចក្ដីសុចរិតនឹងសេចក្ដីពិត។” (អេភេសូរ ៥:៨-៩)

## ស្មោះត្រង់ πίστις

**ការជឿជាក់ ទំនុកចិត្ត ការទុកចិត្ត**

“ព្រះយេស៊ូវមានបន្ទូលទៅគាត់ថា ឲ្យភ្លឺចុះ សេចក្ដីជំនឿអ្នកបានជួយសង្គ្រោះអ្នកហើយ ស្រាប់តែភ្នែកគាត់បានភ្លឺភ្លាម ហើយគាត់ដើរតាមទ្រង់ ទាំងពណ៌នាសរសើរដំកើងព្រះ ឯមនុស្សទាំងអស់ដែលឃើញ ក៏សរសើរដល់ព្រះដែរ។” (លូកា ១៨:៤២-៤៣)

## ស្លូតបូត πραΰτης

**ភាពឱនលំទោន ផ្អែមឡែម អនុគ្រោះ ភាពទន់ភ្លន់ សេចក្ដីគោរព**

“ចូររំឭកគេឲ្យ...ប្រុងប្រៀបធ្វើគ្រប់ទាំងការល្អ មិនត្រូវនិយាយអាក្រក់ពីអ្នកណា ឬឈ្លោះប្រកែកឡើយ ត្រូវមានចិត្តស្លូតបូត ទាំងសំដែងសេចក្ដីសុភាពគ្រប់យ៉ាង ដល់មនុស្សទាំងអស់ផង។” (ទីតុស ៣:១-២)

## ដឹងខ្នាត ἐγκράτεια

**ការចេះគ្រប់គ្រងលើចិត្ត ឬអារម្មណ៍ ចិត្តស្ងប់ស្ងាត់**

“ហើយដោយហេតុនោះបានជាត្រូវឲ្យអ្នករាល់គ្នា បន្ថែមឲ្យមានសេចក្ដីឧស្សាហ៍ដែរ ដើម្បីឲ្យសេចក្ដីជំនឿបានទៀតត្រង់ ឲ្យសេចក្ដីទៀងត្រង់បានដំរិះ ឲ្យដំរិះបានចេះអត់សង្កត់ ឲ្យសេចក្ដីអត់សង្កត់បានខ្ជាប់ខ្ជួន...” (២ពេត្រុស ១:៥-៦)

CHALLIES.com

ផ្លូវពិត plovpit.com